**ឯកសារស្រាវជ្រាវសង្ខេប**

ភូមិភាគ៨ព្រឹទ្ធសភា

# ការចុះបញ្ជីដីសហគមន៍ និងដីសម្បទានសេដ្ឋកិច្ច
# នៅខេត្តមណ្ឌលគិរី

ស្រាវជ្រាវដោយ៖ លោក**លឹម សុវណ្ណារ៉ា**
លោក **ថេង ណាន**

ខែសីហា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ននិងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រម-ព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹម-សារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


បញ្ជីរូបភាព ........................................................................ i

១.សេចក្តីផ្តើម ........................................................................ 1

២.ដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាសមូហភាព ........................ 1

៣.ដីសម្បទានសេដ្ឋកិច្ច ........................................................................ 5

៣.១. គោលបំណងរបស់ដីសម្បទានសេដ្ឋកិច្ច ........................................................ 5

៣.២ ក្របខណ្ឌគតិយុត្តិ ........................................................................ 6

៣.៣. ការផ្អាកបណ្តោះអាសន្នលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗ ................................ 8

៣.៤. ដីសម្បទានសេដ្ឋកិច្ចៈ តួលេខផ្សេងៗគ្នា ........................................................ 9

៣.៥. ដីសម្បទានសេដ្ឋកិច្ចនៅខេត្តមណ្ឌលគីរី ........................................................ 11

៤.បញ្ហាដីទំនាស់ដីធ្លីនៅខេត្តមណ្ឌលគីរី ........................................................ 12

៥. សេចក្តីសន្និដ្ឋាន ........................................................................ 15

គន្ថនិទ្ទេស ........................................................................ 17

ឧបសម្ព័ន្ធ ........................................................................ 18

# បញ្ជីរូបភាព

តួលេខ 1រូបភាពទី១៖ ចំនួនសម្បទាននិកទទួលបានដីសម្បទានសេដ្ឋកិច្ច ឆ្នាំ១៩៩៦ ដល់ ២០១២ ........ 10
តួលេខ 2រូបភាពទី២៖ ផ្ទៃដីសរុបដែលបានផ្តល់ (គិតជាហិកតា) ........ 10
តួលេខ 3រូបភាពទី៣៖ ម្ចាស់កម្មសិទ្ធិរបស់ដីសម្បទានសេដ្ឋកិច្ច ........ 11
តួលេខ 4រូបភាពទី៤៖ និន្នាការទំនាស់ដីធ្លី - ទំនាស់ដីធ្លីថ្មីៗក្នុងមួយឆ្នាំ ........ 13
តួលេខ 5រូបភាពទី៥៖ ចំនួនករណីទំនាស់ដីធ្លីតាមបណ្តាលខេត្ត ........ 13
តួលេខ 6រូបភាពទី៦៖ ទំនាស់ដីធ្លីដែលបណ្តាលមកពីដីសម្បទានសេដ្ឋកិច្ច ........ 14

## ១.សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសកសិកកម្ម ដែលធ្វើឲ្យដីក្លាយជាប្រភពធនធានដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ប្រហែលជា ៨០ ភាគរយនៃប្រជាជនរស់នៅទីជនបទ។[1] ដីបង្កបង្កើនផលសរុបមានចំនួន ៤.១០០.០០០ហិកតា ឬប្រហែលជា ២៣ ភាគរយនៃផ្ទៃដីសរុប។[2] វិស័យកសិកម្មបង្កើតបានការងារសរុបចំនួន ៥១ភាគរយនៅក្នុងប្រទេស និងចូលរួមចំណែក ៣០ភាគរយ ក្នុងផលិតផលក្នុងស្រុកសរុប។[3]

ដើម្បីលើកម្ពស់វិស័យកសិកម្ម ជាពិសេសកសិឧស្សាហកម្ម រដ្ឋាភិបាលកម្ពុជាបានអនុវត្តយន្តការមួយចំនួន។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនឯកជន គឺជាផ្នែកមួយនៃយន្តការទាំងនោះ។ មាត្រា៣ នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច បញ្ជាក់ពីគោលបំណងនៃដីសម្បទានសេដ្ឋកិច្ចថា « *ដើម្បីបង្កើនការងារនៅតាមតំបន់ជនបទជាមួយក្របខណ្ឌនៃប្រពលវប្បកម្ម និងពិពិធកម្មនៃឱកាសចិញ្ចឹមគ្រួសារ និងក្នុងក្របខ័ណ្ឌនៃការ គ្រប់គ្រងធនធានធម្មជាតិដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលសមស្របមួយ*»។ ទោះបីជាយ៉ាងណាក៏ដោយ មានផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនត្រូវបានលើកឡើងពីការអនុវត្តន៍ដីសម្បទានសេដ្ឋកិច្ច ដែលករណីចម្បងមួយគឺទំនាស់រវាងអ្នកទទួលសិទ្ធិលើដីសម្បទាន និងសហគមន៍នៅថ្នាក់មូលដ្ឋាន។ ក្នុងករណីមួយចំនួន ការខកខានរបស់ប្រជាជននៅក្នុងសហគមន៍មូលដ្ឋានក្នុងការចុះបញ្ជីដីធ្លីរបស់ខ្លួនឲ្យបានត្រឹមត្រូវ អាចត្រូវបានគេមើលឃើញថាជាកត្តារួមចំណែកក្នុងទំនាស់ដីធ្លីនៅតំបន់ដីសម្បទាន។

ឯកសារស្រាវជ្រាវសង្ខេបនេះពិនិត្យលើនីតិវិធីតាមផ្លូវច្បាប់សម្រាប់ការចុះបញ្ជីដីធ្លីសហគមន៍ បញ្ហាទាក់ទងទៅនឹងដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តមណ្ឌលគិរី និងទំនាស់ជាមួយសហគមន៍មូលដ្ឋាន។ ឯកសារស្រាវជ្រាវសង្ខេបនេះគឺផ្តល់ព័ត៌មានជាជាងការវិភាគ។

## ២.ដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាសមូហភាព

ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីជនជាតិដើមភាគតិចគឺជាឯកសារគតិយុត្តិសំខាន់ ដែលការពារសិទ្ធិទទួលបានដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេស

[1] Wold Bank data http://data.worldbank.org/country/cambodia (accessed 27 July 2015).
[2] *Ibid.*
[3] *Ibid.*

កម្ពុជា។ ច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការចុះបញ្ជីដីរបស់ពួកគាត់ និងទទួលបានកម្មសិទ្ធិដីសមូហភាព។[4] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩ ចែងអំពីនីតិវិធីសម្រាប់ការចុះបញ្ជីដីរបស់ជនជាតិដើមភាគតិច។[5]

ដំណើរការនៃការចុះបញ្ជីដីជាសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មាន ៣ ដំណាក់កាលធំៗ៖

១) ការកំណត់អត្តសញ្ញាណ និងការទទួលស្គាល់ប្រជាពលរដ្ឋ និងសហគមន៍ជនជាតិដើមភាគតិច

២) ការចុះបញ្ជីបញ្ជីជានីតិបុគ្គល និង

៣) និងការចុះបញ្ជីដីជាសមូសភាព។[6]

មាត្រា៨ នៃអនុក្រឹត្យលេខ ៨៣ តម្រូវឲ្យប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីជនជាតិដើមភាគតិចនីមួយៗ ដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជាកម្មសិទ្ធិសមូហភាពនៅការិយា-ល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកដែលដីតាំងនៅ។ ពាក្យស្នើសុំត្រូវមានការបញ្ជាក់ពីចៅសង្កាត់ មេឃុំថា សហគមន៍ដែលស្នើសុំចុះបញ្ជីដីសហគមន៍ពិតជាសហគមន៍ដែលស្ថិតនៅឃុំសង្កាត់របស់ខ្លួនពិតប្រាកដមែន។[7] ហើយតម្រូវឲ្យមានភ្ជាប់ជាមួយនូវឯកសារដែលចាំបាច់មួយចំនួនផងដែរ ដូចជា៖

- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ដែលមានផ្តិតមេដៃប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី
- លិខិតប្រគល់សិទ្ធិជូនសមាជិកគណៈកម្មាធិការសហគមន៍ណាម្នាក់ជាតំណាងសហគមន៍ក្នុងដំណើរការផ្តល់ព័ត៌មាន ការបញ្ចេញទម្រង់បែបបទក្នុងការចុះបញ្ជីដីសហគមន៍ តាមនីតិវិធីជាធរមាន ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីមិនអាចចូលរួមបាន

---

[4] Land Law 2011, Article 26

[5] Sub-decree No.83 on the Procedures of Registration of Land of Indigenous Communities, ANK/BK, (9 June 2009), http://bit.ly/17FKSZV

[6] *Ibid.*, Article 5

[7] *Ibid.*, Article 8

- លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍ មានសេចក្តីបញ្ជាក់ពីចៅសង្កាត់ ឬមេឃុំ
- បទបញ្ជាផ្ទៃក្នុងសហគមន៍ ទាក់ទងនឹងរបៀបគ្រប់គ្រងនិងការប្រើប្រាស់ដីជាសមូហភាព
- លិខិតជូនដំណឹងស្តីពីការយល់ព្រមឲ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ និង
- រាល់ឯកសារដែលពាក់ព័ន្ធនឹងដីដែលសុំចុះបញ្ជីប្រសិនបើមាន។[8]

ក្រសួងចំនួន៣ ពាក់ព័ន្ធនឹងដំណើរការចុះបញ្ជីនេះ។ ទីមួយ ក្រសួងអភិវឌ្ឍន៍ជនបទទទួលភារកិច្ចក្នុងការកំណត់ និងចេញអត្តសញ្ញាណស្របច្បាប់របស់ប្រជាជន និងសហគមន៍ជនជាតិដើមភាគតិច។ នៅដំណាក់កាលនេះ សហគមន៍ជនជាតិដើមភាគតិចនីមួយៗ តម្រូវឲ្យអនុវត្តនីតិវិធីពីរ៖ ការកំណត់អត្តសញ្ញាណខ្លួនឯង និងការចុះបញ្ជីដើម្បីឲ្យមានការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ។ ទីពីរ ក្រសួងមហាផ្ទៃមានភារកិច្ចក្នុងការឯកភាពទៅលើលក្ខន្តិកៈ នីតិបុគ្គលរបស់សហគមន៍ជនជាតិដើមភាគតិច។ នៅក្នុងដំណើរការនេះ សហគមន៍ជនជាតិដើមភាគតិច ត្រូវតម្រូវឲ្យពិនិត្យទៅលើលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមានការចូលរួមពីសមាជិកទាំងអស់។ និងជាចុងក្រោយ ការចុះបញ្ជីដីសហគមន៍ជាសមូហភាព ដែលជាការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[9]

ក្រោយពីបានទទួលពាក្យសុំចុះបញ្ជីដី ប្រសិនបើ ទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះ មានការឯកភាពពីអ្នកជិតខាង ពីអាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ត្រូវលើកសំណើជូនអភិបាលក្រុង ស្រុក ដើម្បីចេញសេចក្តីជូនដំណឹងជាសាធារណៈក្នុងរយៈពេល ២០ថ្ងៃ យ៉ាងតិចមុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយជាសាធារណៈ នៅកន្លែងដែលងាយមើលឃើញ ដូចជានៅទីស្នាក់ការភូមិ សាលាឃុំ/សង្កាត់ ទីប្រជុំជន និងទីតាំងដីរបស់សហគមន៍សាមី។[10]

[8] *Ibid*.
[9] Men Prachvuthy, *Impacts of Economic Land Concessions on the Livelihoods of Indigenous Communities in Northeast Provinces of Cambodia*, March 2011. P.16-17.
[10] *Ibid*., Article 9

ក្រោយពីការកំណត់ព្រំប្រទល់ និងការវាស់វែងជាក់ស្តែង ទិន្នន័យដែលប្រមូលបានត្រូវបិទផ្សាយជាសាធារណៈរយៈពេល ៣០ ថ្ងៃ នៅក្នុងសហគមន៍សាមី និងសាលាឃុំ/សង្កាត់ ដែលសហគមន៍នោះស្ថិតនៅ។ ក្រោយពីរយៈពេលបិទផ្សាយ និងការតវ៉ាផ្សេងៗ ក្នុងករណីដែលមាន ត្រូវបានដោះស្រាយរួចហើយ រដ្ឋបាលសុរិយោដីត្រូវដំណើរការចុះបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពជូនសហគមន៍តាមនីតិវិធីដូចមានចែងនៅក្នុងមាត្រា១១ នៃអនុក្រឹត្យ។[11]

**ដំណាក់កាលទាំង១៣ នៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាសហកម្មសិទ្ធិ (គម្រោងសាកល្បង)**[12]

១. អ្នកតំណាងសហគមន៍ជនជាតិដើមភាគតិច ត្រូវដាក់ពាក្យសុំចុះបញ្ជីផែនការប្រើប្រាស់ដី និងទាមទារអចលនៈទ្រព្យទៅក្រុមប្រឹក្សាឃុំ/សង្កាត់

២. ក្រុមប្រឹក្សាឃុំ/សង្កាត់ បញ្ចូលផែនការប្រើប្រាស់ដី[13]នៅក្នុងផែនការប្រចាំឆ្នាំរបស់ឃុំ/សង្កាត់ និងបញ្ជូនពាក្យសុំចុះបញ្ជីទៅភូមិបាលក្រុង ស្រុក

៣. ភូមិបាលក្រុង ស្រុក ពិនិត្យលើពាក្យសុំដើម្បីចុះបញ្ជី និងចម្លងទុកផែនការប្រើប្រាស់ដីនៅក្នុងប្រព័ន្ធរបស់ខ្លួន

៤. ភូមិបាលក្រុង ស្រុក បង្កើតគណៈកម្មាធិការផែនការប្រើប្រាស់ដី៖ បង្កើតវិធាន និងបទបញ្ជាផ្ទៃក្នុង និងចរចាជាមួយសហគមន៍ជិតខាង

៥. សហគមន៍ជនជាតិដើមភាគតិច ដាក់ពាក្យសុំចុះបញ្ជី ជានីតិបុគ្គលដើម្បីដំណើរការចុះបញ្ជីដីនៅក្រុមប្រឹក្សាឃុំ/សង្កាត់ និងការិយាល័យខេត្ត

៦. ការិយាល័យខេត្តបង្កើតក្រុមការងារថ្នាក់ខេត្តដើម្បីផ្តល់កម្មសិទ្ធិដី

[11] មាត្រា ១១៖ រដ្ឋបាលសុរិយោដី ត្រូវបង្កើតសៀវភៅគោលបញ្ជីដោយឡែកសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ រដ្ឋបាល សុរិយោដីថ្នាក់ក្រុង ស្រុក ត្រូវចុះបញ្ជីដីសហគមន៍ដែលបានដាក់ពាក្យសុំជាកម្មសិទ្ធិសមូហភាព ក្នុងសៀវភៅគោលបញ្ជីដោយផ្អែកលើទិន្នន័យដែលប្រមូលបានដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ដោយផ្អែកលើលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដែលបានសម្រេចជាផ្លូវការដូចមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យនេះ។ ការចុះបញ្ជីដីរបស់សហគមន៍ត្រូវចុះគ្រប់ផ្នែកនៃក្បាលដីទាំងអស់របស់សហគមន៍នៅលើប្លង់រួមតែមួយ ទោះបីក្បាលដីនោះឋិតនៅក្នុងភូមិឃុំខុសគ្នាក៏ដោយ។ ផ្អែកលើប្លង់រួមមួយនេះ រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាព ជូនសហគមន៍តាមស្ថានភាពជាក់ស្តែងនៃក្បាលដីនីមួយៗ ដោយបញ្ជាក់ឈ្មោះសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលបង្ហាញទីតាំង ទំហំ ព្រំប្រទល់ និយាមការនៃចំណែកដី ដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់នូវប្រភេទនៃការប្រើប្រាស់ដីនិងកំណត់សម្គាល់ផ្សេងៗ។

[12] Land Management Administration Project-LMAP- (2004)

[13] សម្រាប់ព័ត៌មានលំអិតអពីដំណើរការនៃការធ្វើផែនការនេះសូមចូលមើល៖http://www.mekonginfo.org/assets/midocs/0002909-planning-cadastre-participatory-land-use-planning-incambodia-main-report-and-annexes-proceedings-of-the-introductory-workshop-14-15-sep-1999.pdf

៧. ក្រុមការងារថ្នាក់ខេត្តធ្វើការ និងជួយគាំទ្រភូមិបាលក្រុង ស្រុកក្នុងការកំណត់ព្រំ ការវាស់វែង និងវិនិច្ឆ័យ

៨. ភូមិបាលក្រុង ស្រុក ស្នើការគាំទ្រផ្នែកបច្ចេកទេសពីនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រក្នុងការអនុវត្ត/កំណត់ GPS វាស់វែង និងកត់ត្រាទុកនូវដី ដែលអាចមានជម្លោះនៅក្នុងដំបន់សហគមន៍

៩. ពិនិត្យទៅលើរាល់ភស្តុតាងដែលមានទាក់ទងទៅនឹងសិទ្ធិ ទៅលើដីសហគមន៍ដែលត្រូវចុះបញ្ជី

១០. ភូមិបាលក្រុង ស្រុករៀបចំឯកសារវិនិច្ឆ័យ រួមមានទម្រង់របាយការណ៍ដីនិងការវាស់វែងផែនទីដីសហគមន៍ លិខិតបញ្ជាក់ពីស្ថានភាពដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលត្រូវចុះបញ្ជី និង ការឯកភាពទៅលើលក្ខន្តិកៈសហគមន៍ (បិទផ្សាយសាធារណៈរយៈពេល ៣០ថ្ងៃ)

១១. កំឡុងពេលបិទផ្សាយសាធារណៈ ភាគីទំនាស់ទាំងឡាយដែលទាមទារដីសហគមន៍ដែលកំពុងធ្វើការចុះបញ្ជីអាចដាក់ពាក្យប្ដឹងនៅភូមិបាលក្រុង ស្រុក

១២. ក្រោយពីរយៈពេលបិទផ្សាយសាធារណៈ ភូមិបាលក្រុង ស្រុក រៀបចំផែនទីមានលក្ខណៈដាច់ដោយដុំ[14] ហើយបញ្ជូនទៅរដ្ឋបាលសុរិយោដីខេត្ត

១៣. រដ្ឋបាលសុរិយោដីខេត្តផ្ទៀងផ្ទាត់ទៅលើភាពពេញលេញរបស់ឯកសារ ហើយនឹងផ្ញើរទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល។

## ៣.ដីសម្បទានសេដ្ឋកិច្ច

### *៣.១. គោលបំណងរបស់ដីសម្បទានសេដ្ឋកិច្ច*

យោងទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយសារតែវិស័យកសិកម្មគឺជាប្រភពដ៏សំខាន់នៃការងារនិងជាស្នូលនៃសេដ្ឋកិច្ចជនបទ ដូច្នេះចាំបាច់ត្រូវអភិវឌ្ឍវិស័យនេះដើម្បីកសាង និងរក្សាកំណើនសេដ្ឋកិច្ច និងដើម្បីពន្លឿនការកាត់បន្ថយភាពក្រីក្រ។[15] រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំពុងលើកទឹកចិត្តឲ្យមានពិពិធកម្មដំណាំ និងបង្កើនផលិតភាព។ ដីសម្បទានសេដ្ឋកិច្ចត្រូវបានគេមើលឃើញថា

---

[14]អនុក្រឹត្យ លេខ ៤៨ ស្ដីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឆ្នាំ២០០២៖ «....ផែនទីដែលមានលក្ខណៈដាច់ដោយដុំគឺជាប្លង់សុរិយោដីដែលបង្ហាញពីទីតាំង លេខ និងព្រំប្រទល់នៃក្បាលដីទាំងឡាយដែលបានចុះបញ្ជីរួច និងក្បាលដីដែលស្នើសុំចុះបញ្ជី បន្ទាប់ពីបិទផ្សាយជាសាធារណៈនិងបានបញ្ចប់ការសម្រុះសម្រួលនិងការដោះស្រាយទំនាស់»។

[15]Royal Government of Cambodia, National Strategic Development Plan Update 2009-2013, p, 121.

ជាឧបករណ៍ដ៏សំខាន់សម្រាប់ការសម្រេចបាននូវគោលបំណងទាំងនេះ។[16] អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចកំណត់ពីការផ្តួចផ្តើមដីសម្បទានសេដ្ឋកិច្ចថាជា «យន្តការមួយរបស់រដ្ឋាភិបាលក្នុងការផ្តល់ដីសាធារណៈឯកជនតាមរយៈកិច្ចសន្យាដី សម្បទានសេដ្ឋកិច្ចជាក់លាក់មួយ ដល់សម្បទានិកដើម្បីប្រើប្រាស់សម្រាប់ការប្រកបរបរកសិកម្ម និងកសិឧស្សាហកម្ម។»[17] មាត្រា២ ក៏បានបញ្ជាក់បន្ថែមទៀតថា«ការបង្កបង្កើនផលកសិឧស្សាហកម្ម » គឺជា៖

- ការដាំដុះដំណាំអាហារ ឬដំណាំឧស្សាហកម្ម រួមបញ្ចូលទាំងការដាំដើមឈើដើម្បីបង្កើតជាចំការដើមឈើ
- ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
- ការសាងសង់ដូចជា រោងចក្រនិងកន្លែងសម្រាប់កែច្នៃវត្ថុធាតុដើមក្នុងវិស័យកសិកម្មក្នុងស្រុក ឬ
- ការរួមបញ្ចូលគ្នាមួយចំនួន ឬទាំងអស់នៃសកម្មភាពខាងលើនេះ។

បើយោងទៅតាមអនុក្រឹត្យ គោលបំណងសំខាន់នៃគោលនយោបាយនេះ មានដូចខាងក្រោម៖ ដើម្បីធ្វើការអភិវឌ្ឍន៍វិស័យកសិកម្មនៅថ្នាក់មូលដ្ឋាន និងដើម្បីលើកកម្ពស់កម្រិតការវិនិយោគទុនដំបូងនៅក្នុងវិស័យកសិឧស្សាហកម្ម។ ដើម្បីបង្កើនឱកាសការងារនៅតាមតំបន់ជនបទក្នុងក្របខ័ណ្ឌនៃការបង្កើនឱកាស ជីវភាព និងការគ្រប់គ្រងធនធានធម្មជាតិ ផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលសមស្របមួយ។ និងដើម្បីបង្កើតប្រាក់ចំណូលថ្នាក់ជាតិ ខេត្ត ឬឃុំ/សង្កាត់ ពីកម្រៃសម្បទាន ពន្ធ និងថ្លៃសេវាផ្សេងៗ។[18]

### *៣.២ ក្របខណ្ឌ័គតិយុត្តិ*

ច្បាប់ភូមិបាលឆ្នាំ២០០១ និង អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចឆ្នាំ២០០៥ គ្រប់គ្រងការផ្តល់ដីសម្បទាន។ ខណៈពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ កំណត់បទប្បញ្ញត្តិទូទៅពាក់ព័ន្ធសម្រាប់ចេញដីសម្បទានទាំងអស់រួមទាំងសម្រាប់គោលបំណងសង្គម និងសេដ្ឋកិច្ច (មាត្រា៤៨-៦២) អនុក្រឹត្យស្តីពី

[16] Open Development of Cambodia, "Economic Land Concessions (ELCs)" http://www.opendevelopmentcambodia.net/briefing/economic-land-concessions-elcs/ (accessed 24 July 2015).
[17] Art. 2 Sub Decree on Economic Land Concession, Royal Government of Cambodia, No. 146 ANK/BK, 27.12.2005.
[18] PrachVuthy, Men, "Land Governance for Equitable and Sustainable Development," March, 2011, p, 19.

ដីសម្បទានសេដ្ឋកិច្ច បានដាក់ចេញតម្រូវការខាងផ្លូវច្បាប់ ចំពោះការផ្តល់ដីសម្បទានសេដ្ឋកិច្ច។[19] យោងទៅតាមមាត្រា៥ នៃអនុក្រឹត្យ ១៤៦ ការវាយតម្លៃនៃសំណើដីសម្បទានសេដ្ឋកិច្ចគួរតែផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

(១) បង្កើនផលិតផលកសិកម្ម និងកសិឧស្សាហកម្មដោយប្រើប្រាស់បច្ចេកទេសទំនើប

(២) បង្កើតឱកាសការងារ

(៣) លើកកម្ពស់ជីវភាពរបស់ប្រជាជន

(៤) ការគ្រប់គ្រងការការពារបរិស្ថាននិងធនធានធម្មជាតិ

(៥) ជៀសវាងទាំងស្រុង ឬធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានតិចតួចបំផុតដល់សង្គម

(៦) ទំនាក់ទំនងណាមួយ និង ការគាំទ្រវាងដីសម្បទានសង្គមកិច្ច និងដីសម្បទានសេដ្ឋកិច្ច និង

(៨) ការកែច្នៃវត្ថុធាតុដើមកសិកម្ម។

អំណាចក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។[20] កាលពីមុន អាជ្ញាធរថ្នាក់ក្រោមជាតិអាចផ្តល់ដីសម្បទានសេដ្ឋកិច្ចទំហំតូចរហូតដល់ ១.000 ហិកតា[21] ប៉ុន្តែជម្រើសនេះ ត្រូវបានលុបចោលនៅឆ្នាំ២០០៨។[22]

ទំហំដីសម្បទានសេដ្ឋកិច្ចធំបំផុតគឺ១០.០០០ហិចតា[23] និងរយៈពេលវែងបំផុត ៩៩ឆ្នាំ។[24] ពត៌មានលម្អិតចាំបាច់ត្រូវបានបង្កើតឡើង ដោយការចុះកិច្ចសន្យាដីសម្បទានរវាងអ្នកទទួលបានសិទ្ធិសម្បទាន និងអាជ្ញាធរ។[25] ដីសម្បទានអាចត្រូវដកហូតវិញបាន ដោយការសម្រេចចិត្តរបស់រដ្ឋាភិបាល ឬអាចត្រូវបានលុបចោលដោយតុលាការក្នុងករណីមិនបានគោរពលក្ខខណ្ឌច្បាប់ឲ្យបានត្រឹមត្រូវ។[26] ដីសម្បទានសេដ្ឋកិច្ច អាចត្រូវបានទទួលបានដោយស្ថាប័នបរទេស ឬ អង្គភាពរបស់កម្ពុជាដែលមាន

---

[19] Christoph Oldenburg and AdreasNeef, "Competing Frameworks and Perspectives on Land Property in Cambodia," Paper prepared for the 2013 Law and Development Conference, Legal and Development Implications of International Land Acquisitions, Kyoto, Japan, 30-31 May 2013. p. 5.

[20] Art. 29 Sub Decree on Economic Land Concession, Royal Government of Cambodia, No. 146 ANK/BK, 27.12.2005.

[21] *Ibid*.

[22] Art. 1, Sub Decree on Modification of the Sub Decree on Economic Land Concession 2008.

[23] Art. 59 Land Law (promulgated on 30 August 2001).

[24] The Ministry of Environment announced on 28 July 2015 that the length of ELCs was limited to 50 years. See also Art. 61 of Land Law.

[25] *Ibid*., Art. 53.

[26] *Ibid*., Art. 55.

ការគ្រប់គ្រងដោយជនបរទេស ១០០ ភាគរយ។[27] សម្បទានអាចត្រូវបានផ្តល់ក្នុងបីទម្រង់៖ សេដ្ឋកិច្ច (សម្រាប់ប្រើប្រាស់កសិឧស្សាហកម្ម) សង្គមកិច្ច (សម្រាប់ប្រើប្រាស់ជាលំនៅដ្ឋាននិងការចិញ្ចឹមជីវិត) និងផ្សេងទៀត (ដូចជា ការរុករករ៉ែ ឬការអភិវឌ្ឍន៍ឧស្សាហកម្ម)។ ដីសម្បទានសេដ្ឋកិច្ចនិងដីសម្បទានសង្គមកិច្ចមានលក្ខណៈដូចគ្នាដូចតទៅ៖ អាចផ្តល់សម្បទានបានបន្ទាប់ពីដីសាធារណៈរបស់រដ្ឋត្រូវបានបម្លែងទៅជាដីឯកជនរបស់រដ្ឋតែប៉ុណ្ណោះ។[28]

### *៣.៣. ការផ្អាកបណ្តោះអាសន្នលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗ*

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា លោកបានចុះហត្ថលេខាលើសារាចរ ចាប់ផ្តើមផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី និងការអនុវត្តគោលនយោបាយហៅថា «គោលនយោបាយស្បែកខ្លា»[29] ដែលទាក់ទងទៅនឹងដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ដើម្បីដកចេញពីតំបន់ដែលមានមនុស្សរស់នៅសម្បទាន និងការកាត់បន្ថយការទន្ទ្រានលើកសិករ និងដីសហគមន៍។[30] សារាចរលេខ ០០១ ក៏បានអំពាវនាវឲ្យមានការពិនិត្យឡើងវិញលើដីសម្បទានដែលមានស្រាប់ទាំងអស់ នៅក្នុងគោលបំណងដើម្បីពិនិត្យមើលការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ សារាចរលេខ០០១ នេះបានបញ្ជាក់ជាថ្មីថា សម្បទានដែលបានរកឃើញថាមានការរំលោភផ្នែកច្បាប់ និងរំលោភលើកិច្ចសន្យា នឹងត្រូវបានលុបចោល។[31]

យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្មនៅឆ្នាំ២០១៤ គិតត្រឹមឆ្នាំ២០១៤ «ដោយសារតែភាពអសកម្មលើផែនការវិនិយោគរបស់ពួកគេ» ដីសម្បទានសរុបចំនួន៦៩កន្លែង ដែលមានទំហំដីចំនួន ៥៨៧,៥៨០ ហិកតា ត្រូវបានលុបកិច្ចសន្យាចោលដោយរដ្ឋាភិបាល។ ក្នុងចំណោមដីសម្បទានទាំងនោះ មានដីសម្បទាន ៦១ កន្លែង ធំជាង ១.០០០ហិកតា មានផ្ទៃដីសរុបចំនួន ៥៨០,៦៦៧ ហិកតា និង ៨ កន្លែងផ្សេងទៀត តូចជាង ១.០០០ ហិកតា ដែលមានផ្ទៃសរុប ៦.៩១៣ ហិកតា។[32]

---

[27] Art. 8 Sub Decree on ELC.

[28] Andreas Neef and Siphat Touch, "Land Grabbing in Cambodia: Narratives, Mechanisms, Resistance." Land Deal Politics Initiative. Global Land Grabbing II, October 17-19, 2012.

[29]The "leopard skin" policy allows the authorities to cut out the overlapped areas from ELC concessionaires for the local communities.

[30] ADHOC, A Turning Point? Land, Housing and Natural Resources – Rights in Cambodia in 2012, February 2013, p. 34.

[31] *Ibid.*, p. 34.

[32]MAFF Annual Report 2014, p, 25.http://www.maff.gov.kh/reports/68-annualreport/1268-2015-05-28-07-02-59.html (accessed 27 July 2015).

### ៣.៤. ដីសម្បទានសេដ្ឋកិច្ច៖ តួលេខផ្សេងៗគ្នា

ដូចដែលបានរៀបរាប់ខាងលើ អំណាចផ្តល់ដីសម្បទានសេដ្ឋកិច្ចស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទោះបីជាយ៉ាងណាក៏ដោយ តាមពិតដីសម្បទានសេដ្ឋកិច្ចអាចត្រូវបានផ្តល់ដោយស្ថាប័នផ្សេងៗទៀតដូចជាក្រសួងបរិស្ថាន។[33] ទាំងនេះបានធ្វើឲ្យមានតួលេខខុសៗគ្នាយ៉ាងខ្លាំងនៃចំនួនក្រុមហ៊ុនដែលទទួលបានដីសម្បទាន និងទំហំដីសម្បទានសរុប។ ទិន្នន័យដែលទទួលបានពីក្រសួងកសិកម្មបានបង្ហាញថា គិតត្រឹមថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ ក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ចមាន ១២១ ក្រុមហ៊ុន ជាមួយនឹងផ្ទៃដីសរុប ១,២០៤,៧៥០ ហិកតា។[34] របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម នៅឆ្នាំ២០១៤ បង្ហាញថាចំនួនដីសម្បទានមានចំនួន ១២១ នៅក្នុងខេត្តចំនួន ១៨ ជាមួយផ្ទៃដីសរុបចំនួន ១,៣១៥,៤៨២។[35] ដូចដែលនឹងមានបង្ហាញក្នុងកថាខ័ណ្ឌខាងក្រោម អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើបញ្ហាដីធ្លីមានតួលេខខុសគ្នាទាក់ទងនឹងដីសម្បទានសេដ្ឋកិច្ច។

យោងតាមរបាយការណ៍របស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) បានបញ្ជាក់ថា «គិតត្រឹមចុងខែធ្នូ ឆ្នាំ២០១២ រដ្ឋាភិបាលបានបម្រុងទុក ឬក៏បានផ្តល់យ៉ាងហោចណាស់ ២.៦៥៧.៤៧០ ហិកតា ទៅឲ្យក្រុមហ៊ុនឯកជនក្រោមគម្រោងដីសម្បទានសេដ្ឋកិច្ច»។[36] របាយ-ការណ៍នេះបានបន្ថែមថា «នៅក្នុងឆ្នាំ២០១២ តែមួយប៉ុណ្ណោះ រដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន ៦៦ រក្សាទុកដី ៣៨១.១២១ហិកតា សម្រាប់ដីសម្បទានសេដ្ឋកិច្ចដោយរួមបញ្ចូលទាំងអនុក្រឹត្យចំនួន ៣៣ បន្ទាប់ពីការប្រកាសនៃការផ្អាកបណ្តោះអាសន្ន លើការផ្តល់ដីសម្បទានសេដ្ឋកិច្ច(នៅថ្ងៃទី០៧ ខែឧសភាឆ្នាំ២០១២)។[37] យោងតាមទិន្នន័យចុងក្រោយបានពីអង្គការសិទ្ធិមនុស្សមួយផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែលមានឈ្មោះថា សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) ដីសម្បទានសេដ្ឋកិច្ចគ្របដណ្តប់ផ្ទៃដី ២.១១៩.០៨២ហិកតា។[38]

---

[33] Protected Area Law, 2008.

[34] The figure from the website puts it at 117 companies and 1,181,522 hectares. However, according to the author's calculation based on the same list, the number of concessionaires is 12 with a total land area of 1,204,750 hectares. http://www.maff.gov.kh/ accessed 24 July 2015.

[35]MAFF Annual Report 2014, p. 25.http://www.maff.gov.kh/reports/68-annualreport/1268-2015-05-28-07-02-59.html (accessed 27 July 2015).

[36] ADHOC, A Turning Point? Land, Housing and Natural Resources – Rights in Cambodia in 2012, February 2013, p. 9.

[37] *Ibid.*, p. 9.

[38]http://www.licadho-cambodia.org/land_concessions/maps/map-overview-small.jpg (accessed 24 July 2015).

ទិន្នន័យពីក្រសួងកសិកម្មបានបង្ហាញថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមានកម្រិតខ្ពស់បំផុតគឺក្នុងឆ្នាំ២០១១ ដែលមានក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ចចំនួន២៤ មានផ្ទៃដីសរុបចំនួន ១៨៤.៥៧៦ ហិកតា។ ទោះជាយ៉ាងណាក៏ដោយ ដីសម្បទានសេដ្ឋកិច្ចភាគច្រើនត្រូវបានផ្តល់នៅចន្លោះឆ្នាំ២០០០ និង ឆ្នាំ២០០១ ដែលមានផ្ទៃដីសរុបចំនួន ៤០៨.៤០៤ ហិកតា។

### រូបភាពទី១៖ ចំនួនសម្បទាននិកទទួលបានដីសម្បទានសេដ្ឋកិច្ច ឆ្នាំ១៩៩៦ ដល់២០១២




*ប្រភព៖ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ*

### រូបភាពទី២៖ ផ្ទៃដីសរុបដែលបានផ្តល់ (គិតជាហិតា)




*ប្រភព៖ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ*

### ៣.៥. ដីសម្បទានសេដ្ឋកិច្ចនៅខេត្តមណ្ឌលគិរី

យោងតាមទិន្នន័យពីក្រសួងកសិកម្មបង្ហាញថា គិតត្រឹមថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ មានក្រុមហ៊ុនចំនួន១៤ (ឧបសម្ព័ន្ធទី១) បានទទួលដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាលដែលមានផ្ទៃដីសរុបចំនួន ១០១.០៣៦ហិកតា។ ភាគច្រើននៃដីទាំងនេះត្រូវបានប្រើសម្រាប់ដំណាំកៅស៊ូ ខណៈពេលដែលដីនៅសល់ គឺសម្រាប់ដំណាំកសិ-ឧស្សាហកម្មដទៃទៀត ដូចជាដើមអាកាស្យា ល្ហុងខ្វង និងស្រល់។ មិនមានទិន្នន័យដែលអាចរកបានស្តីពីការផលិត ការនាំចេញ ការងារ និងប្រាក់ខែរបស់កម្មករទេ។ ក្រុមហ៊ុនដែលទទួលបានសម្បទានទាំង១៤ មិនមានក្រុមហ៊ុនណាមួយមានគេហទំព័រនោះទេ។

ដូចជាទិន្នន័យថ្នាក់ជាតិដែរ ទិន្នន័យស្តីពីដីសម្បទានសេដ្ឋកិច្ចរបស់ខេត្តមណ្ឌលគិរី គឺមានភាពខុសគ្នាខ្លាំង។ ខណៈពេលដែលក្រសួងកសិកម្ម បានបង្ហាញក្រុមហ៊ុនទទួលដីសម្បទានមានចំនួន១៤ ក្រុមហ៊ុន និងផ្ទៃដីសរុបចំនួន ១០១.០៣៦ហិកតា ទិន្នន័យទទួលបានពីទិន្នន័យអំពីការអភិវឌ្ឍន៍ (Open Development of Cambodia) បានបង្ហាញថា មានចំនួន៣១ក្រុមហ៊ុន (ឧបសម្ព័ន្ធ២) (ក្នុងនោះមានបីក្រុមហ៊ុនទទួលបានតិចជាង ១.០០០ ហិកតា) ត្រូវបានទទួលដីសម្បទានសេដ្ឋកិច្ចនៅខេត្តមណ្ឌលគិរី ជាមួយនឹងទំហំដីដែលទទួលបានសរុបចំនួន ២០៨.៥១០ហិកតា។

ដូចដែលបានរៀបរាប់ខាងលើ ព័ត៌មានលម្អិតស្តីពីដីសម្បទានសេដ្ឋកិច្ចដែលបានផ្ដើសម្បទានគឺហាក់បីដូចជាមានភាពមិនច្បាស់លាស់។ ទិន្នន័យពីអង្គការលីកាដូ បានបង្ហាញថា ជិត ៥០ភាគរយនៃផ្ទៃដីសម្បទានសេដ្ឋកិច្ចសរុប ត្រូវបានសម្បទានទៅឲ្យក្រុមហ៊ុនដែលមានម្ចាស់ជាជនជាតិកម្ពុជា ជាកម្ម-សិទ្ធិ (៩០៦.១៦១ ហិកតា) បន្ទាប់មកកម្មសិទ្ធិដោយជនជាតិវៀតណាម (៣៦៣.៥៦០ហិកតា) កម្មសិទ្ធិជនជាតិចិន ស្ថិតក្នុងលេខរៀងទីបីចំនួន ៣៥៥.៥០៣ហិកតា។ លេខរៀងទីបួន និងទីប្រាំត្រូវបានកាន់កាប់ដោយជនជាតិសឹង្ហបុរី និងជនជាតិ ម៉ាឡេស៊ី មានចំនួន ១១២.០៨៨ហិកតា និង ៩០.៨៤៤ហិកតា ជាបន្តបន្ទាប់។[39]

### រូបភាពទី៣៖ ម្ចាស់កម្មសិទ្ធិរបស់ដីសម្បទានសេដ្ឋកិច្ច

[39] *Ibid.*




ប្រភព៖អង្គការលីកាដូ ( http://www.licadho-cambodia.org/land_concessions/maps/map-ownership-small.jpg ) accessed 31 July 2015.

## ៤.បញ្ហាទំនាស់ដីធ្លីនៅខេត្តមណ្ឌលគិរី

យោងទៅតាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) ទំនាស់ដីធ្លីកើតមានទៅលើដីប្រភេទផ្សេងៗគ្នា ដូចជាដីកសិកម្ម( ដីកសិដ្ឋាន និងដីស្រែ) ដីលំនៅដ្ឋាន និងដីព្រៃ។ ភាគច្រើននៃទំនាស់កើតមានឡើងនៅលើដីកសិកម្ម។[40] កត្តាជាច្រើនដែលបណ្តាលឲ្យមានទំនាស់ដីធ្លី រួមទាំងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង និងតំបន់ជនបទ ដីសម្បទានសេដ្ឋកិច្ច ដីសម្បទានផ្សេងទៀតដែលដំណើរការ ដោយក្រុមហ៊ុនជាតិ និងអន្តរជាតិ និងការចាប់យកដីធ្លីជាលក្ខណៈបុគ្គល។[41]

ដូចដែលមានបង្ហាញក្នុងរូបភាពទី៤ បញ្ហាទំនាស់ដីធ្លីមិនមែនជាបាតុភូតថ្មីទេនៅក្នុងប្រទេសកម្ពុជា។ ទំនាស់ដីធ្លីថ្មីចំនួន ២៨ ត្រូវបានកត់ត្រាក្នុងឆ្នាំ ២០១៣។ ចំនួននេះគឺមានកម្រិតទាបបើប្រៀបធៀបទៅនឹងករណីដែលកើតមានឡើងក្នុងអំឡុងឆ្នាំ ២០១០ ២០១១ និងឆ្នាំ២០១២ ដោយមានចំនួន ៣៩, ៣៩ និងទំនាស់ថ្មីចំនួន៤៦ ជាបន្តបន្ទាប់។[42]

---

[40] NGO Forum on Cambodia, Statistical Analysis on Land Disputes in Cambodia, 2010. Phnom Penh, June 2011. p. 4.

[41] NGO Forum on Cambodia, Statistical Analysis on Land Disputes in Cambodia, 2013. Phnom Penh, September 2014. p. 1.

[42] *Ibid.,* p. 7.

## រូបភាពទី៤៖ និន្នាការទំនាស់ដីធ្លី - ទំនាស់ដីធ្លីថ្មីៗក្នុងមួយឆ្នាំ




*ប្រភព៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា*

បើបំបែកតាមខេត្ត (សូមមើលរូបទី៤) នៅរាជធានីភ្នំពេញមានបញ្ហាទំនាស់ដីធ្លីច្រើនជាងគេបំផុតមានរហូតដល់ ២៩ ករណី ខណៈពេលដែលខេត្តប៉ៃលិន និងខេត្តកែបមានតែមួយករណី។ ១៥ករណីត្រូវបានកត់ត្រានៅក្នុងខេត្តមណ្ឌលគីរី។ ទាំង ១៥ ករណីនោះបានប៉ះពាល់រហូតដល់ ៣.២៣២ គ្រួសារ។[43]

## រូបភាពទី៥៖ ចំនួនករណីទំនាស់ដីធ្លីតាមបណ្តាលខេត្ត

[43] *Ibid.,* 16.




*ប្រភព៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា*

ដូចដែលបានបញ្ជាក់ខាងលើ ក្នុងចំណោមកត្តាផ្សេងៗ ដីសម្បទានសេដ្ឋកិច្ចត្រូវបានគេបញ្ជាក់ថាជាមូលហេតុ ដែលបង្កឲ្យមានទំនាស់ដីធ្លី។ គួរឲ្យភ្ញាក់ផ្អើល ក្នុងចំណោមបញ្ហាទំនាស់ដីធ្លីចំនួន១៥ ដែលបានកត់ត្រាក្នុងខេត្តមណ្ឌលគីរី មាន ១២ ករណី ត្រូវបានបង្កឡើងដោយការផ្តល់ដីសម្បទានសេដ្ឋកិច្ច។[44] ក្នុងន័យនេះ ខេត្តមណ្ឌលគិរី ជាខេត្តមួយដែលមានទំនាស់ដីធ្លីច្រើនជាងគេបំផុតដែលបង្កឡើងដោយដីសម្បទានសេដ្ឋកិច្ច។ អ្នកស្រាវជ្រាវមិនអាចរកឃើញព័ត៌មានពីចំនួនករណីដែលត្រូវបានដោះស្រាយហើយ ពាក់ព័ន្ធនឹងទំនាស់ដីធ្លីទាំង ១៥ ករណីនោះទេ។

## រូបភាពទី៦៖ ទំនាស់ដីធ្លីដែលបណ្តាលមកពីដីសម្បទានសេដ្ឋកិច្ច

[44] *Ibid.,* p. 22.




*ប្រភព៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា*

## ៥. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាគឺជាប្រទេសដែលប្រកបរបរកសិកម្មលើសលុប ដែលធ្វើឲ្យដីក្លាយជាធនធានដ៏មានតម្លៃបំផុតសម្រាប់ប្រជាជនកម្ពុជា។ ការបង្កើតការងារនៅថ្នាក់មូលដ្ឋាន និងការអភិវឌ្ឍន៍កសិ-ឧស្សាហកម្មជាមូលហេតុពីរដ៏សំខាន់នៅពីក្រោយការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនបានកើតឡើងពីការធ្វើសម្បទាននេះ។ ខណៈពេលដែលទំនាស់ដីធ្លីគឺមិនមែនជាបាតុភូតថ្មីទេនៅប្រទេសកម្ពុជា ចំនួននៃវិវាទដីធ្លីបានកើនឡើងទាក់ទងនឹងការផ្តល់ដីសម្បទានសេដ្ឋកិច្ចនោះ។ ក្នុងករណីមួយចំនួន ទំនាស់កើតមានរវាងសហគមន៍ជនជាតិដើមភាគតិច និងសម្បទានិក។ ការចុះបញ្ជីដីត្រឹមត្រូវអាចធ្វើឲ្យស្រាល ឬកាត់បន្ថយទំនាស់ទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការចុះបញ្ជីដីធ្លីនេះគឺមានភាពស្មុគស្មាញរួចទៅហើយសម្រាប់សហគមន៍មូលដ្ឋាន។

ទិន្នន័យដែលទាក់ទងដីសម្បទានសេដ្ឋកិច្ច ដែលបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺមិនត្រូវគ្នានឹងទិន្នន័យដែលបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើបញ្ហា

ជីធ្លីនេះទេ។ ព័ត៌មានដែលមិនត្រូវគ្នា ធ្វើឲ្យកាន់តែលំបាកបន្ថែមទៀតក្នុងការវាយតម្លៃពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចដូចជាចំនួនកម្មករមានការងារធ្វើ និងប្រាក់បៀវត្សរ៍របស់ពួកគេ ផ្ទៃដីដាំដុះ និងទិន្នផលដំណាំ។ ប្រសិនបើមិនទាំងអស់ទេ ក៏ភាគច្រើននៃសម្បទានិក មិនមានគេហទំព័រឡើយ។

ច្បាប់ភូមិបាលឆ្នាំ ២០០១ និងអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចដែលបានចេញនៅក្នុងឆ្នាំ២០០៥ គ្រប់គ្រងការផ្តល់ដីសម្បទាននៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ នៅមានចន្លោះប្រហោងមួយចំនួនតូចដែលមានការបើកចំហរក្នុងការបកស្រាយដែលតម្រូវឲ្យមានការបំភ្លឺ។ ការផ្អាកបណ្តោះអាសន្ននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ថ្មីៗ ឬបទបញ្ជា០០១ ដែលបានបញ្ជាក់ថា ដីសម្បទានដែលរកឃើញថារំលោភច្បាប់ និងរំលោភកិច្ចសន្យា នឹងត្រូវបានលុបចោល បានកែតម្រូវចំណុចមួយចំនួននៃចន្លោះប្រហោងទាំងនោះ។ យន្តការត្រួតពិនិត្យ និង ការវាយតម្លៃលើការអនុវត្តជាច្រើនទៀតនៃដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ គួរតែត្រូវបានអនុវត្ត។

ការត្រួតពិនិត្យកាន់តែប្រសើរឡើងត្រូវតម្រូវឲ្យមាន ដើម្បីធានាថា ដីសម្បទានសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ហើយត្រូវផ្តល់ផលសេដ្ឋកិច្ចវិជ្ជមានដល់សហគមន៍ក្នុងតំបន់និងនៅក្នុងប្រទេសកម្ពុជាទាំងមូល។

# គន្ថនិទ្ទេស

ADHOC, A Turning Point? Land, Housing and Natural Resources – Rights in Cambodia in 2012, February 2013.

Andreas Neefad and Siphat Touch, "Land Grabbing in Cambodia: Narratives, Mechanisms, Resistance." Land Deal Politics Initiative. Global Land Grabbing II, October 17-19, 2012.

Christoph Oldenburg and AdreasNeef, "Competing Frameworks and Perspectives on Land Property in Cambodia," Paper prepared for the 2013 Law and Development Conference, Legal and Development Implications of International Land Acquisitions, Kyoto, Japan, 30-31 May 2013.

Sub Decree on Modification of the Sub Decree on Economic Land Concession 2008.LICADHO, http://www.licadho-cambodia.org/land_concessions/maps/map-overview-small.jpg (accessed 24 July 2015).

Men Prachvuthy, *Impacts of Economic Land Concessions on the Livelihoods of Indigenous Communities in Northeast Provinces of Cambodia*, March 2011.

Ministry of Agriculture Forestry and Fisheries, Annual Report, 2014.http://www.maff.gov.kh/reports/68-annualreport/1268-2015-05-28-07-02-59.html (accessed 27 July 2015).

Ministry of Land Management, Urban Planning and Construction, Land Management and Administration Project (LMAP) (2004).

NGO Forum on Cambodia, Statistical Analysis on Land Disputes in Cambodia, 2010. Phnom Penh, June 2011.

NGO Forum on Cambodia, Statistical Analysis on Land Disputes in Cambodia, 2013. Phnom Penh, September 2014.

Open Development of Cambodia, http://www.opendevelopmentcambodia.net/briefing/economic-land-concessions-elcs/ (accessed 24 July 2015).

Royal Government of Cambodia, Land Law, 30 August2011.

Royal Government of Cambodia, National Strategic Development Plan Update 2009-2013.

Royal Government of Cambodia, Protected Area Law(2008).

Royal Government of Cambodia, Sub-decree No. 48 on Sporadic Land Registration, 2002.

Royal Government of Cambodia, Sub Decree on Economic Land Concession, No. 146 ANK/BK, 27.12.2005.

Royal Government of Cambodia,Sub-decree No.83 on the Procedures of Registration of Land of Indigenous Communities, ANK/BK, (09 June 2009).

World Bank data http://data.worldbank.org/country/cambodia (accessed 27 July 2015).

# ឧបសម្ព័ន្ធ

**Appendix 1: Economic Land Concessions in Mondulkiri Province**

| No. | Concessionaire name | Location (district) | Area (hectares) | Type of crop | Date of contract |
|---|---|---|---|---|---|
| 1 | Covyphama Co., Ltd. | PichChreada | 5,345 | rubber | 17.02.2008 |
| 2 | DakLakMondulkiri Rubber Development | PichChreada, OuReang, KohNhek | 4,162 | rubber | 04.07.2008 |
| 3 | KhaouChuly Development (KCD) | PichChreada | 2,346 | rubber | 08.10.2008 |
| 4 | Seang Long Green Land Investment (Cambodia) Co., Ltd. | KeoSeyma, PichChreada | 7,000 | rubber and acacia | 08.12.2008 |
| 5 | Land & Developing (Cambodia) | KeoSeyma, PichChreada | 7,000 | rubber and acacia | 08.12.2008 |
| 6 | Unigreen Resources Co, Ltd. | KohNhek | 8,000 | rubber | 03.04.2009 |
| 7 | DCT Group | KohNhek | 4,000 | rubber | 18.03.2009 |
| 8 | Mo Hy Pa MasuOrn Cambodia JV | KeoSeyma | 7,800 | rubber and jatropha | 29.01.2010 |
| 9 | Huor Ling (Cambodia) International | OuReang, SenMonorom | 8,400 | pine | 05.05.2010 |
| 10 | Pacific Lotus Joint-Stock Company Limited | KohNhek | 9,014 | rubber | 09.09.2011 |
| 11 | Pacific Pearl Joint-Stock Company Limited | KohNhek | 9,614 | rubber | 09.09.2011 |
| 12 | Pacific Grand Joint-Stock Company Limited | KohNhek | 9,656 | rubber | 09.09.2011 |
| 13 | Pacific Pride Joint-Stock Company Limited | KohNhek | 9,773 | rubber | 09.09.2011 |
| 14 | BenhHoeurkKratie Rubber 1 Company Limited | KeoSeyma | 8,926 | rubber | 24.01.2011 |
| **Total** | | | **101,036** | | |

Source: Ministry of Agriculture, Forestry and Fisheries (MAFF) http://www.maff.gov.kh/ accessed 24 July 2015.

**Appendix2: Economic Land Concessions in Mondulkiri Province**

| No. | Concessionaire name | Location | Area | Investment intention | Investor country | Director nationality | Contract date |
|---|---|---|---|---|---|---|---|
| 1 | Covyphama Co., Ltd. | PichChreada | 5,345 | rubber | Cambodia | Cambodian | 17.02.2008 |
| 2 | DakLakMondulkiriAphivathCaouthcouch | PichChreada, OuReang, KohNhek | 4,162 | rubber | Not found | Not found | 04.07.2008 |
| 3 | Varanasi (KhaouChuly Development) | PichChreada | 2,346 | rubber | Not found | Not found | 08.10.2008 |
| 4 | Seang Long Green Land Investment (Cambodia) Co., Ltd. | PichChreada, KeoSeyma | 7,000 | rubber and acacia | China | Chinese | Not found |
| 5 | Land & Developing (Cambodia) | Pich Chreada and KeoSeyma | 7,000 | rubber and acacia | China | Chinese | 08.12.08 |
| 6 | Unigreen Resource | KohNhek | 8,000 | rubber | China | Chinese | 03.04.2009 |
| 7 | D.T.C (Group) | PichChreada | 4,000 | rubber | Cambodia | Cambodian | 18.03.2009 |
| 8 | Mo Hy Pa MasuOrn Kampuchea Co., Ltd. | KeoSeyma | 7,800 | rubber | Not found | Malaysian | 29.01.2010 |
| 9 | Hour Ling (Cambodia) International Insurance | OuReang, SenMonorom | 8,400 | pine | China | Chinese | 05.05.2010 |
| 10 | Pacific Lotus Joint-Stock Company Limited | KohNhek | 9,014 | rubber | Not found | Not found | 09.09.2011 |
| 11 | Pacific Pearl Joint-Stock Company Limited | KohNhek | 9,614 | rubber | Not found | Not found | 09.09.2011 |
| 12 | Pacific Grand Joint-Stock Company Limited | KohNhek | 9,656 | rubber | Vietnam | Not found | 09.09.2011 |
| 13 | Pacific Pride Joint-Stock Company Limited | KohNhek | 9,773 | rubber | Vietnam | Not found | 09.09.2011 |
| 14 | BenhHoeurkKratie Rubber 1 Company Limited | KeoSeyma | 8,926 | rubber | Vietnam | Vietnamese | 24.10.2011 |
| 15 | Eastern Rubber (Cambodia) | KeoSeyma | 10,000 | | Not found | Not found | 24.10.2011 |
| 16 | HengHeanSiv Chan Tour Trading Co., Ltd. | PichChreada, SenMonorom, OuReang | 4,000 | rubber and other crops | Not found | Not found | Not found |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 17 | Investment and Development Dai Nam (Cambodia) J.S.C Ltd. | KeoSeyma | 8,685 | agro-industry crops | Not found | Not found | Not found |
| 18 | Investment and Development Dai Thanh (Cambodia) J.S.C Ltd. | Not found | 8,708 | Not found | Not found | Not found | Not found |
| 19 | Kasekam Khmer Angkor Co., Ltd. | Not found | 9,160 | agro-industry crops and rubber | Cambodia | Not found | Not found |
| 20 | L K I construction Co., Ltd. | Not found | 5,559 | agro-industry crops | Not found | Not found | Not found |
| 21 | Lim Royal Joint Stock Company Limited | Not found | 9,068 | agro-industry crops | Cambodia | Not found | Not found |
| 22 | Master K Son Co., Ltd. | Not found | 9,892 | rubber | Not found | Not found | Not found |
| 23 | Mega First Corporation Berhad (MFCB) | Not found | 9,477 | Agro-industry, ecotourism and SEZ | Malaysia | Not found | Not found |
| 24 | MondulAgri-Resource Co., Ltd. | KohNhek | 9,100 | rubber | Not found | Cambodian | 25.09.2009 |
| 25 | RetthyKiriSeyma Cp., Ltd. | KeoSeyma | 5,000 | rubber and agro-industry | Not found | Not found | Not found |
| 26 | Sethikula Co., Ltd. | PichChreada | 4,273 | rubber | Cambodia | Not found | Not found |
| 27 | Veranasi (KhaouChuly Development) | PichChreada | 2,705 | rubber | France | Not found | Not found |
| 28 | Wuzhishan L.S Group | OuReang, SenMonorom | 10,000 | processing factory | China | Chinese | 30.12.2005 |
| 29 | K Peace Investment (Cambodia) Co., Ltd. | Not found | 500 | agro-industry crops and rubber | Not found | Not found | Not found |
| 30 | Sitthi Agriculture Plantation Co., Ltd. | PichChreada | 522 | Rubber | Not found | Not found | Not found |
| 31 | Villa Development Co., Ltd. | PichChreada | 825 | Not found | Not found | Not found | Not found |
| **Total** | | | **208,** | | | | |

| | | |
|---|---|---|
| | **510** | |

Source: Open Development Cambodia
http://www.opendevelopmentcambodia.net/company-profiles/economic-land-concessions/ (accessed 28 July 2015).